ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២១ លេខ ១ ខែមីនា ២០១៧ តម្លៃ ១.៥០០៛

# តើថ្នាក់ដឹកនាំផ្នែកសិក្សាស្រាវជ្រាវនៅកម្ពុជា បានកំណត់ និងមានចំណាប់អារម្មណ៍យ៉ាងណាលើ អន្តរជាតូបនីយកម្មឧត្តមសិក្សា

## សេចក្តីផ្តើម

សាកលភាវូបនីយកម្ម និងការអភិវឌ្ឍក្នុងតំបន់យ៉ាងខ្លាំងក្លា ដែលកើតមានឡើងតាំងពីដើមទសវត្សរ៍១៩៩០ បាននាំឲ្យមានកំណើនគួរឲ្យកត់សម្គាល់នូវ សកម្មភាពអន្តរជាតិក្នុងអនុវិស័យឧត្តមសិក្សាទូទាំងសកលលោក។ ពីឆ្នាំ២០០០ ដល់ ២០១៣ ចំនួននិស្សិតចេញទៅបន្តការសិក្សាថ្នាក់ឧត្តមសិក្សានៅបរទេស បានកើនមួយជាពីររហូតដល់ ៤,១លាននាក់ ត្រូវជា ១,៨% នៃចំនួននិស្សិតសរុប ដែលរៀនថ្នាក់ឧត្តមសិក្សាក្នុងទូទាំងពិភពលោក (UIS2016)។ សហរដ្ឋអាមេរិកជាប្រទេសគោលដៅទាក់ទាញខ្លាំងជាងគេ ដោយបានស្រូបយកនិស្សិតអន្តរជាតិចល័តជាង ១៩% ក្នុងឆ្នាំ២០១៣ បន្ទាប់មកគឺ អង់គ្លេស (១0%) អូស្ត្រាលី (៦%) បារាំង (៦%) និងអាឡឺម៉ង់ (៥%)។ នៅឆ្នាំ២០១៦ ប្រទេសបួនដែលមាននិស្សិតចេញទៅរៀននៅបរទេសច្រើនជាងគេគឺ ចិន (៨០១.១៨៧នាក់) ឥណ្ឌា (២៥៥.០៣០នាក់) អាឡឺម៉ង់ (១១៦.៣៤២នាក់) និងកូរ៉េខាងត្បូង (១០៨.០៤៧នាក់) (UIS 2017)។ សកម្មភាពផ្សេងទៀតក៏មានកំណើនគួរឲ្យកត់សម្គាល់ដែរ ដូចជា ការបង្កើតសាខាគ្រឹះស្ថានឧត្តមសិក្សាបរទេស កិច្ចសហការស្រាវជ្រាវ និងកម្មវិធីសិក្សាសញ្ញាបត្ររួម។ នៅកម្រិតគោលនយោបាយវិញ អន្តរជាតូបនីយកម្ម បានវិវត្តពីលក្ខណៈតូចតាចទៅជាចំណុចស្នូលមួយនៃ គោលនយោបាយថ្នាក់ជាតិ និងថ្នាក់ស្ថាប័នក្នុងប្រទេសជាច្រើន។



*សកម្មភាពអន្តរជាតូបនីយកម្មក្នុងឧត្តមសិក្សា បានកើនឡើងនៅក្នុងប្រទេសកម្ពុជា*
*វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ខែកុម្ភៈ ២០១៧។*

នៅកម្ពុជា សកម្មភាពអន្តរជាតូបនីយកម្មក្នុងឧត្តមសិក្សាបានកើនឡើង តាំងពីប្រទេសនេះ បានចាប់ផ្តើមចូលសហគមន៍នៅក្នុងតំបន់ និងអន្តរជាតិ នៅដើមទសវត្សរ៍១៩៩០។ សកម្មភាពទាំងនេះ រួមមាន ភាពចល័តរបស់និស្សិតនិងសាស្ត្រាចារ្យ ការស្រាវជ្រាវរួមគ្នា និងភាពជាដៃគូអន្តរជាតិ។ ចំនួននិស្សិតចេញទៅរៀនថ្នាក់ឧត្តមសិក្សា នៅបរទេសក្នុងឆ្នាំ២០១៦ មានចំនួន

## មាតិកា

តើថ្នាក់ដឹកនាំផ្នែកសិក្សាស្រាវជ្រាវនៅកម្ពុជាបានកំណត់ និងមានចំណាប់អារម្មណ៍យ៉ាងណាលើ អន្តរជាតូបនីយកម្មឧត្តមសិក្សា.................................... ១
ឥទ្ធិពលនៃការចូលរួមរបស់អ្នកស្រុកទៅលើទស្សនៈ និងការគាំទ្រដល់សហគមន៍អេកូទេសចរណ៍នៅកម្ពុជា៖ វិធីសាស្ត្រ ម៉ូដែលសមីការជាប្រព័ន្ធ................................ ៨
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ...................... ១៤
— ស្ថានភាពក្នុងប្រទេស...................... ១៦
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ......................................២៤

តឹក ម៉ុយទៀង ជាជំនួយការស្រាវជ្រាវ និង បណ្ឌិត ឡេង ភីរម្យ ជាអ្នកស្រាវជ្រាវនៅផ្នែកអប់រំ នៅវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថា: Tek Muy Tieng and Leng Phirom. 2017. “How do Cambodian Academic Leaders Define and Perceive Higher Education Internationalisation?” *Cambodia Development Review* 21(1): 1-7.

ក្រុមអ្នកនិពន្ធ សូមថ្លែងអំណរគុណដល់ ក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) នៃប្រទេសអូស្ត្រាលី ចំពោះជំនួយគាំទ្រហិរញ្ញវត្ថុដ៏សប្បុរសដល់ការស្រាវជ្រាវនេះ។

៥.២៧៥នាក់ ស្មើនឹង ២,៤% (UIS 2017)។ ដូចមានចុះនៅក្នុង តារាង១ ប្រទេសគោលដៅចម្បងៗ (គិតតាមលំដាប់សារៈសំខាន់) របស់និស្សិតកម្ពុជា គឺ ថៃ អូស្ត្រាលី បារាំង សហរដ្ឋអាមេរិក និង វៀតណាម។ អ្នកផ្ដល់សេវាអប់រំបរទេសជាច្រើនដែលមានទីតាំងនៅកម្ពុជា រួមមាន សាកលវិទ្យាល័យលីមកុកវីងរបស់ម៉ាឡេស៊ី សាលារៀនអន្តរជាតិរាហ្វល របស់អូស្ត្រាលី ព្រមទាំងការិយាល័យប្រចាំនៅកម្ពុជានៃ សាកលវិទ្យាល័យជប៉ុនពីរ គឺ ណាហ្គូយ៉ា និង ហ៊ីរ៉ូស៊ីម៉ា ដែលផ្ដល់កម្មវិធីសិក្សាថ្នាក់ក្រោយឧត្តមសិក្សាផ្នែកអភិវឌ្ឍន៍ (សាកលវិទ្យាល័យណាហ្គូយ៉ា) និងផ្នែកអប់រំ (សាកលវិទ្យាល័យហ៊ីរ៉ូស៊ីម៉ា)។

តារាង១៖ ប្រទេសគោលដៅចម្បងៗប្រាំរបស់និស្សិតកម្ពុជាក្នុងឆ្នាំ២០១៦

| ប្រទេសគោលដៅ | ចំនួននិស្សិត |
|---|---|
| ថៃ | 1182 |
| អូស្ត្រាលី | 784 |
| បារាំង | 611 |
| សហរដ្ឋអាមេរិក | 527 |
| វៀតណាម | 381 |

ប្រភព៖ UNESCO Institute of Statistics (2017)

ទោះបីមានកំណើនសកម្មភាពយ៉ាងនេះក្ដី ឯកសារស្រាវជ្រាវអំពីអន្តរជាតូបនីយកម្មឧត្តមសិក្សានៅកម្ពុជា នៅមានតិចតួចនៅឡើយនាបច្ចុប្បន្ន ហើយសាធារណជន ក៏មានការយល់ឃើញខុសៗគ្នាពីផ្នែកនេះដែរ។ ការសិក្សាពីឧត្តមសិក្សានៅកម្ពុជាក្នុងទសវត្សរ៍១៩៩០ និងដើមទសវត្សរ៍២០០០ ផ្ដោតជាសំខាន់លើកម្លាំងអំណាច ជាពិសេស ឥទ្ធិពលរបស់រដ្ឋាភិបាល និងទីភ្នាក់ងារបរទេស ទៅលើគ្រឹះស្ថានឧត្តមសិក្សាក្នុងស្រុក តាមរយៈជំនួយផ្នែកអប់រំរបស់ពួកគេ (Pit and Ford 2004; Clayton 2006)។ ដូច្នេះហើយ ការសិក្សានេះ មានគោលដៅស្វែងយល់ពីការដាក់និយមន័យ និងការយល់ឃើញរបស់ ថ្នាក់ដឹកនាំផ្នែកសិក្សាស្រាវជ្រាវនៅកម្ពុជា អំពីពាក្យ "អន្តរជាតូបនីយកម្មឧត្តមសិក្សា" ក្នុងស្ថានភាពដែលប្រទេសកម្ពុជា កាន់តែមានការចូលរួមច្រើនឡើងនៅក្នុងតំបន់ និងអន្តរជាតិ។ ជាបន្ត ឯកសារនេះ នឹងបង្ហាញពីក្របខ័ណ្ឌគោលគំនិតនៃការសិក្សា បន្ទាប់មក វិធីសាស្ត្រស្រាវជ្រាវ លទ្ធផលរកឃើញនិងការពិភាក្សា និងការផ្ដល់ជាមតិមួយចំនួននៅចុងបញ្ចប់។

## ក្របខ័ណ្ឌគោលគំនិត

ផ្នែកនេះ ផ្ដល់នូវក្របខ័ណ្ឌគោលគំនិតសម្រាប់ការស្រាវជ្រាវ ដោយដំបូងអ្នកស្រាវជ្រាវ ពិនិត្យពីនិយមន័យ បន្ទាប់មកពីចំណាប់អារម្មណ៍ខុសៗគ្នាលើអន្តរជាតូបនីយកម្ម។ អន្តរជាតូបនីយកម្មនៃឧត្តមសិក្សា ចាប់ផ្ដើមមានការពេញនិយមយ៉ាងខ្លាំងក្នុងពីរទសវត្សរ៍កន្លងមក ប៉ុន្តែពាក្យផ្សេងៗទៀត ដូចជា សហប្រតិបត្តិការអន្តរជាតិ ការអប់រំអន្តរជាតិ ទំនាក់ទំនងអន្តរជាតិ មានយកមកប្រើតាំងពីទសវត្សរ៍ ១៩៦០ ម្ល៉េះ។ ដើមឡើយ ពាក្យ "អន្តរជាតូបនីយកម្ម" សំដៅដល់ សកម្មភាពមួយឈុតដែលទាក់ទងនឹងការសិក្សាឬកម្មវិធីសិក្សាអន្តរជាតិ និងការអប់រំផ្នែកភាសា (Knight 2008)។ ចាប់ពីពេលនោះមក ពាក្យនេះ បានវិវត្តក្នុងបរិបទមានការផ្លាស់ប្ដូរជាច្រើនក្នុង ឧត្តមសិក្សានៅទូទាំងសាកលលោក ហើយវាក៏ត្រូវបានដាក់និយមន័យ និងយល់ឃើញខុសៗគ្នា ពីសំណាក់អ្នកពាក់ព័ន្ធមកពីវិស័យផ្សេងៗគ្នា។ និយមន័យដែលគេលើកឡើងជាញឹកញាប់ គឺរបស់ Knight (2008, 21) ដែលពិពណ៌នាពីអន្តរជាតូបនីយកម្មឧត្តមសិក្សាថាជា "ដំណើរការនៃការដាក់បញ្ចូលធាតុ អន្តរជាតិ អន្តរវប្បធម៌ ឬសកល ទៅក្នុង គោលដៅ មុខងារ ឬការផ្ដល់សេវាអប់រំថ្នាក់ឧត្តមសិក្សា"។ និយមន័យនេះ មានលក្ខណៈពិសេសព្រោះវាមានន័យអព្យាក្រឹត ដោយផ្ដល់គំនិតថា ដំណើរការនេះ អាចមានភាពវិជ្ជមាន ឬអវិជ្ជមាន ឬក៏អាចមានទាំងពីរមុខ ទៅតាមបែបបទដែលគេពិនិត្យមើលវា។

ការសិក្សាមួយនៅឆ្នាំ២០១៥ ធ្វើឡើងដោយ សភាអឺរ៉ុប បានរកឃើញថា សាកលវិទ្យាល័យនានាគួរយកចិត្តទុកដាក់ទៅលើគុណភាពកម្មវិធីសិក្សារបស់ខ្លួន និងលទ្ធផលរៀនសូត្ររបស់និស្សិត (បញ្ហាក្នុងស្រុក) ជាជាងផ្ដោតតែទៅលើសកម្មភាពនៅក្រៅប្រទេស។ ដោយពង្រីកនិយមន័យគោលរបស់ Knight សភាអឺរ៉ុបបានឲ្យនិយមន័យអន្តរជាតូបនីយកម្មថាជា"ដំណើរការដោយចេតនានៃការដាក់បញ្ចូល ធាតុ អន្តរជាតិ អន្តរវប្បធម៌ ឬសកល ទៅក្នុងគោលដៅ មុខងារ ឬការផ្ដល់សេវាអប់រំថ្នាក់ឧត្តមសិក្សា ដើម្បីលើកស្ទួយគុណភាពនៃការអប់រំ និងស្រាវជ្រាវ សម្រាប់និស្សិត និងបុគ្គលិកទាំងអស់ និងដើម្បីចូលរួមដោយមានន័យក្នុងការអភិវឌ្ឍសង្គម" (de Wit et al. 2015)។ និយមន័យនេះ មានការរាប់បញ្ចូលមនុស្សគ្រប់គ្នា និងផ្អែកលើគំនិតចង់ឲ្យមានសមធម៌ក្នុងសង្គម ដោយកំណត់ឲ្យអន្តរជាតូបនីយកម្មមានលក្ខណៈសម្រាប់គ្រប់គ្នា ជាជាង សម្រាប់តែនិស្សិតនិងក្រុមសាស្ត្រាចារ្យមួយចំនួនតូចដែលបានចេញទៅបរទេស។

មតិទិតៀនមួយទៀតដល់និយមន័យរបស់ Knight កើតចេញពី Hawawini (2016) ដែលបានរកឃើញនៅក្នុងការសិក្សារបស់គាត់ស្ដីពី អន្តរជាតូបនីយកម្មនៃគ្រឹះស្ថានឧត្តមសិក្សា និងសាលាពាណិជ្ជកម្មថា អន្តរជាតូបនីយកម្ម មិនគួរកំណត់ព្រំដែនឲ្យតូចចង្អៀត ត្រឹមតែ ដំណើរការដាក់បញ្ចូលធាតុអន្តរជាតិទៅក្នុងរចនាសម្ព័ន្ធស្ថាប័ន និងលំនាំមានស្រាប់ (ដំណើរការឯកទិស ជាជាង ដំណើរការទ្វេទិស) នោះទេ។ ដូច្នេះហើយ គាត់បានស្នើឡើងនូវនិយមន័យថ្មីមួយនៃ អន្តរជាតូបនីយកម្មឧត្តមសិក្សាថាជា "ដំណើរការកំពុងទៅមុខនៃការផ្លាស់ប្ដូរដែលមានគោលដៅដាក់បញ្ចូលស្ថាប័ន និងអ្នកពាក់ព័ន្ធសំខាន់ៗ (និស្សិត និងសាស្ត្រាចារ្យ) ទៅក្នុងសេដ្ឋកិច្ចសកលផ្អែកលើចំណេះដឹងដែលកំពុងផុសឡើង" (Hawawini 2016, 5)។ ស្រដៀងគ្នាដែរ ប៉ុន្តែផ្អែកលើគំនិតវិភាគតាមលក្ខណៈទីតាំង Larsen (2016, 10) បានកំណត់និយមន័យអន្តរជាតូបនីយកម្មឧត្តមសិក្សាថាជា "ការពង្រីកវិសាលភាពសាកលវិទ្យាល័យ ឲ្យហួសពីព្រំដែនប្រទេស តាមរយៈភាពចល័តនៃនិស្សិត អ្នកស្រាវជ្រាវ ចំណេះដឹង

តារាង២៖ ហេតុផលបួននៃការធ្វើអន្តរជាតូបនីយកម្មគ្រឹះស្ថានឧត្តមសិក្សា

| | |
|---|---|
| សង្គម/វប្បធម៌ | អត្តសញ្ញាណវប្បធម៌ជាតិ<br>ការយោគយល់អន្តរវប្បធម៌<br>ការអភិវឌ្ឍភាពជាពលរដ្ឋ<br>ការអភិវឌ្ឍសង្គម និងសហគមន៍ |
| នយោបាយ | គោលនយោបាយការបរទេស<br>សន្តិសុខជាតិ<br>ជំនួយបច្ចេកទេស<br>សន្តិភាព និងការយោគយល់គ្នា<br>អត្តសញ្ញាណជាតិ<br>អត្តញ្ញាណក្នុងតំបន់ |
| សេដ្ឋកិច្ច | កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែង<br>ទីផ្សារពលកម្ម<br>គ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ |
| សិក្សាស្រាវជ្រាវ | ការពង្រីកព្រំដែននៃការសិក្សា<br>ការកសាងស្ថាប័ន<br>កេរ្តិ៍ឈ្មោះ និងឋានៈ<br>ការលើកកម្ពស់គុណភាព<br>ស្តង់ដាសិក្សាអន្តរជាតិ<br>ការបញ្ចូលធាតុអន្តរជាតិទៅក្នុងការស្រាវជ្រាវ និងបង្រៀន |

ប្រភព៖ Knight (2004)

កម្មវិធីសិក្សា និងអ្នកផ្តល់សេវាអប់រំ"។ ថ្វីបើមានភាពល្អៀងន័យគ្នាខ្លះ ការសិក្សានេះ បានវែកញែកថា អំណះអំណាងទាំងនោះ គឺមានភាពដូចគ្នាជាច្រើនជាមួយនឹង លក្ខណៈស្នូលនៃនិយមន័យរបស់ Knight (2008) ដែលគ្របដណ្តប់លើធាតុជាច្រើន ទាំង "នៅក្នុងស្រុក" និង "នៅក្រៅស្រុក"។ ដូច្នេះ ឯកសារស្រាវជ្រាវនេះបានយកនិយមន័យរបស់Knightមកប្រើជាក្របខ័ណ្ឌសម្រាប់ពិនិត្យពីបែបបទដែល អ្នកដឹកនាំផ្នែកសិក្សាស្រាវជ្រាវនៅកម្ពុជាកំណត់និយមន័យឲ្យពាក្យ "អន្តរជាតូបនីយកម្មឧត្តមសិក្សា"។

សព្វថ្ងៃនេះ មានមតិចម្រុះគ្នាជាច្រើនអំពី ដំណើរការអន្តរជាតូបនីយកម្ម។ ម្យ៉ាង មានមនុស្សជាច្រើនមើលឃើញអន្តរជាតូបនីយកម្ម ថាជា ឱកាសក្នុងការផ្តល់ការអប់រំឲ្យបានស្មើភាពគ្នាដល់ អ្នកដែលកំពុងស្វែងរក ឱកាសរៀនសូត្រ។ គំនិតវិជ្ជមាននេះ ជាទូទៅផុសចេញពី ហេតុផលបួនដែលគាំទ្រឲ្យមានអន្តរជាតូបនីយកម្មឧត្តមសិក្សា ពោលគឺ ហេតុផលផ្នែកសង្គម/វប្បធម៌ នយោបាយ សេដ្ឋកិច្ច និងសិក្សាស្រាវជ្រាវ (Knight 2004; de Wit 2002) ដូចមានចុះក្នុង តារាង២។ ហេតុផលទាំងនេះ មិនមានលក្ខណៈដាច់ពីគ្នានោះទេ ប៉ុន្តែសារៈសំខាន់របស់ហេតុផលនីមួយៗ អាចប្រែប្រួលទៅតាមពេលវេលា និងទីកន្លែង។

ដូច Knight (2008, 25) បានបង្ហាញស្រាប់ "ហេតុផលនីមួយៗ បានចង្អុលតម្រង់ទៅប្រភេទនៃអត្ថប្រយោជន៍ ឬលទ្ធផលរំពឹងទុកផ្សេងៗដែលអ្នកចូលរួមគិតថា អាចទទួលបានពីកិច្ចប្រឹងប្រែងធ្វើអន្តរជាតូបនីយកម្ម"។ ប៉ុន្តែទន្ទឹមនឹងការទទួលស្គាល់នូវអត្ថប្រយោជន៍ទាំងនេះ មានមនុស្សជាច្រើន បានលើកឡើងថា ពិភពលោកត្រូវបានកំណត់ឡើងដោយវិសមភាព ហើយអន្តរជាតូបនីយកម្មនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ កើតមានឡើងដោយត្រូវមានការលះបង់ច្រើន។ យោងតាម Altbach and Knight (2007) និង Hoppers (2000) មូលនិធិធំៗសម្រាប់ការស្រាវជ្រាវ និងអាហារូបករណ៍ កន្លងមកផ្តោតជាសំខាន់ទៅលើគ្រឹះស្ថានឧត្តមសិក្សានៅតាមបណ្តាប្រទេសអភិវឌ្ឍន៍ ដូចជា សហរដ្ឋអាមេរិក កាណាដា និងប្រទេសនៅទ្វីបអឺរ៉ុបមួយចំនួន ដែលនៅទីនោះមានធនធានបណ្ណាល័យនិងមន្ទីរពិសោធន៍យ៉ាងសម្បូរបែប និងមានមូលធនមនុស្សប្រកបដោយគុណភាពខ្ពស់។ ប្រទេសទាំងនោះ មើលឃើញនិស្សិតអន្តរជាតិបង់ថ្លៃជា ប្រភពចំណូលដ៏សំខាន់របស់ខ្លួន។ និស្សិតអន្តរជាតិបង់ថ្លៃមួយចំនួន ក្រោយមកក៏ក្លាយជាជនអន្តោប្រវេសន៍មានជំនាញខ្ពស់ សម្រាប់ជួយទ្រទ្រង់ការរីកចម្រើនសេដ្ឋកិច្ចក្នុងប្រទេសអភិវឌ្ឍន៍ទាំងនោះ ដោយសារពួកគេមើលឃើញថា ប្រទេសទាំងនោះមានលក្ខខណ្ឌការងារល្អប្រសើរជាងនៅក្នុងប្រទេសកំណើតរបស់ខ្លួន។ តួយ៉ាង សមាមាត្រនៃជនចំណាកស្រុកចេញពីប្រទេសអាស៊ាននានា ទៅកាន់បណ្តាប្រទេសសមាជិក អង្គការសម្រាប់សហប្រតិបតិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) បានកើនឡើងយ៉ាងគំហុកដល់ប្រមាណ ៦៦% ក្នុងរយៈពេល ១០ឆ្នាំ ពីត្រឹម ១.៦៧៩.៤៥៣នាក់ នៅឆ្នាំ២០០១ រហូតដល់ ២.៧៩១.៧២៧នាក់ នៅឆ្នាំ២០១១ (Batalova, Shymonyak, and Sugiyarto 2017, 14)។ បញ្ហាលំហូរចេញធនធានខួរក្បាលនេះ មានផលប៉ះពាល់អវិជ្ជមានខ្លាំងណាស់ទៅលើការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៃប្រទេសកំពុងអភិវឌ្ឍន៍។

ម្យ៉ាងទៀត អន្តរជាតូបនីយកម្មក្នុងលក្ខណៈជាមធ្យោបាយសម្រាប់លើកស្ទួយភាសាអង់គ្លេស ហើយនិងចំណេះដឹង វប្បធម៌ និងតម្លៃសីលធម៌របស់បស្ចឹមប្រទេស គឺជា ការខាតបង់មួយ

សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (Altbach and Knight 2007; Altbach 2013)។ ឧទាហរណ៍ជាក់ស្តែងមួយ គឺការផុសឡើងនាពេលថ្មីៗនូវ វគ្គបណ្តុះបណ្តាលតាមអនឡាញ (MOOCs)។ ថ្វីបើគេចាត់ទុកវាជាមធ្យោបាយពង្រីក លទ្ធភាពទទួលបានការអប់រំថ្នាក់ឧត្តមសិក្សាជាសកលក្តី MOOCs ភាគច្រើនមានលក្ខណៈតាមបែបបស្ចិមប្រទេស ដោយសារអ្នកផ្តល់សេវាអប់រំធំៗភាគច្រើនស្ថិតនៅក្នុងប្រទេសអភិវឌ្ឍន៍ (Altbach 2014)។ ដោយមូលហេតុនេះ Altbach (2014) និង Hughes (2008) បានរិះគន់ថា ក្នុងករណីខ្លះ អន្តរជាតូបនីយកម្ម គឺជាទម្រង់មួយនៃ អាណានិគមនិយមបែបថ្មី។ ស្រដៀងគ្នាដែរ Mazrui (1975) បានពិនិត្យពីផលប៉ះពាល់អវិជ្ជមាននៃ អន្តរជាតូបនីយកម្មឧត្តមសិក្សានៅទ្វីបអាហ្វ្រិកក្នុងទសវត្សរ៍១៩៦០ និង១៩៧០ ហើយបានលើកឡើងថា វាគ្រាន់តែជាទម្រង់មួយនៃការពឹងផ្អែកផ្នែកវប្បធម៌ ហើយគាត់កត់សម្គាល់ឃើញថា គ្រឹះស្ថានឧត្តមសិក្សានៅអាហ្វ្រិក ដើរតួនាទីជាក្រុមហ៊ុនពហុជាតិបរទេសដែលបម្រើផលប្រយោជន៍ឲ្យបស្ចិមប្រទេស ជាជាងបម្រើប្រជាជនអាហ្វ្រិក។ គាត់បានផ្តល់យុទ្ធសាស្ត្រ បី សម្រាប់ប៉ះប៉ូវផលប៉ះពាល់អវិជ្ជមាននៃការពឹងផ្អែកផ្នែកវប្បធម៌នេះ។ ទី១ គឺ យុទ្ធសាស្ត្រធ្វើមូលដ្ឋានីយកម្ម តាមរយៈការផ្សារភ្ជាប់មុខវិជ្ជាក្នុងកម្មវិធីសិក្សានៅសាកលវិទ្យាល័យអាហ្វ្រិក ទៅនឹងវប្បធម៌ និងចំណេះដឹងក្នុងស្រុក។ គាត់ផ្តល់គំនិតបន្ថែមថា ភាពស្ទាត់ជំនាញរបស់និស្សិតក្នុងផ្នែកភាសា ប្រវត្តិសាស្ត្រ នវិទ្យាផ្នែកសង្គមនិងវប្បធម៌ គួរតែជាលក្ខខណ្ឌចាំបាច់ដាច់ខាត សម្រាប់ការទទួលសិស្សឲ្យចូលរៀននៅសាកលវិទ្យាល័យ។ ទី២ គឺ យុទ្ធសាស្ត្រធ្វើពិពិធកម្មដែលអំពាវនាវឲ្យ (គ្រឹះស្ថានឧត្តមសិក្សា) កសាងកម្មវិធីសិក្សាមួយមានលក្ខណៈសកលពិតៗ។ ក្នុងនេះ គាត់បានផ្តល់យោបល់ថា សាកលវិទ្យាល័យអាហ្វ្រិក គួរផ្តោតមិនត្រឹមតែទៅលើអារ្យធម៌អឺរ៉ុប និងអាហ្វ្រិកប៉ុណ្ណោះទេ ប៉ុន្តែគួរផ្តោតទៅលើអារ្យធម៌ឥណ្ឌា ចិន និង អ៊ីស្លាមផងដែរ។ ទី៣ គឺ យុទ្ធសាស្ត្រទប់ទល់ការជ្រៀតចូល (នៃចំណេះដឹងនិងមនោគមវិជ្ជាបរទេស) តាមរយៈការបង្កើតក្រុមសីលធម៌ពិសេសមួយ សម្រាប់ភាពជាអ្នកសិក្សាស្រាវជ្រាវដែលអាចមានឥទ្ធិពលទៅលើ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនានាក្នុងពិភពលោក។

## វិធីសាស្ត្រ

ការសិក្សានេះ បានប្រើប្រាស់គំរូការស្រាវជ្រាវតាមបែបគុណភាពដែល Creswell (2012, 16) បានជជែកការពារថាជាវិធីសាស្ត្រសមស្របបំផុតសម្រាប់ការស្រាវជ្រាវពីបញ្ហាថ្មីៗ ឬប្រធានបទដែលមិនសូវមានការសិក្សាលើនោះ។ ក្នុងរយៈពេល ៦ ខែ (ពីខែសីហា ២០១៦ ដល់ មករា ២០១៧) ក្រុមស្រាវជ្រាវបានធ្វើសម្ភាសន៍ស៊ីជម្រៅចំនួន ១៤ ជាមួយអ្នកគ្រប់គ្រងជាន់ខ្ពស់ក្នុងសាកលវិទ្យាល័យកម្ពុជាចំនួន ៦ (៣ ជារបស់ឯកជន និង ៣ ជារបស់រដ្ឋ) នៅទីក្រុងភ្នំពេញ និងនៅតាមខេត្ត។ ការជ្រើសរើសអ្នកឆ្លើយសម្ភាសន៍ បានធ្វើឡើងតាមការដៅទុករបស់អ្នកស្រាវជ្រាវ ដោយផ្អែកលើកត្តាបទពិសោធន៍ និងការចូលរួមក្នុងសកម្មភាពអន្តរជាតូបនីយកម្មនៅតាមស្ថាប័នរបស់ពួកគាត់។ ក្រុមស្រាវជ្រាវ បានយកទិន្នន័យប្រមូលបានមកវិភាគតាមបែបគុណភាព ដើម្បីស្វែងយល់ពីបែបបទដែលអ្នកចូលរួមម្នាក់ៗបានកំណត់និយមន័យ និងយល់ឃើញពីការធ្វើអន្តរជាតូបនីយកម្មនៅកម្ពុជា។ ក្រុមស្រាវជ្រាវ បានប្រើរហស្សនាមដូចមានចុះក្នុង តារាង ៣ ដើម្បីរក្សាការសម្ងាត់ជូនដល់អ្នកចូលរួមក្នុងការសិក្សានេះ។

តារាង៣៖ បញ្ជីអ្នកចូលរួម និងតួនាទីក្នុងអង្គភាព

| អ្នកចូលរួម | ស្ថាប័នពាក់ព័ន្ធ | តួនាទី |
|---|---|---|
| SI1 | សាកលវិទ្យាល័យ A | សាកលវិទ្យាធិការរងសម្រាប់កិច្ចការសិក្សា |
| SI2 | សាកលវិទ្យាល័យ B | នាយករងសម្រាប់កិច្ចសហប្រតិបត្តិការ និងការស្រាវជ្រាវ |
| SI3 | សាកលវិទ្យាល័យ C | ប្រធានការិយាល័យទំនាក់ទំនងអន្តរជាតិ |
| PI1 | សាកលវិទ្យាល័យ D | សាកលវិទ្យាធិការរងសម្រាប់ទំនាក់ទំនងសាកលវិទ្យាល័យ និងកិច្ចការនិស្សិត |
| PI2 | សាកលវិទ្យាល័យ D | សាកលវិទ្យាធិការរងជាន់ខ្ពស់សម្រាប់កិច្ចការសិក្សា |
| PI3 | សាកលវិទ្យាល័យ D | នាយកកម្មវិធីសិក្សាអន្តរជាតិ |
| PI4 | សាកលវិទ្យាល័យ D | នាយក (សាកលវិទ្យាល័យសាខា) |
| PI5 | សាកលវិទ្យាល័យ D | នាយកជំនួយការ (សាកលវិទ្យាល័យសាខា) |
| PI6 | សាកលវិទ្យាល័យ D | នាយកជំនួយការរង (សាកលវិទ្យាល័យសាខា) |
| PI7 | សាកលវិទ្យាល័យ E | អ្នកសម្របសម្រួលកិច្ចការអន្តរជាតិ |
| PI8 | សាកលវិទ្យាល័យ E | នាយកផ្នែកស្រាវជ្រាវ |
| PI9 | សាកលវិទ្យាល័យ E | សាស្ត្រាចារ្យ |
| PI10 | សាកលវិទ្យាល័យ E | ប្រធានដេប៉ាតឺម៉ង់ថែទាំអ្នកជំងឺ |
| PI11 | សាកលវិទ្យាល័យ F | នាយករង (សាកលវិទ្យាល័យសាខា) |

រូបភាព១៖ ពាក្យប្រើនៅក្នុងចក្ខុវិស័យរបស់គ្រឹះស្ថានឧត្តមសិក្សាទាំង ៦ ដែលស្ថិតក្នុងការស្រាវជ្រាវនេះ




| ពាក្យ | ប្រេកង់ |
|---|---|
| ការអប់រំ | 8 |
| កម្ពុជា | 7 |
| គុណភាព | 6 |
| អន្តរជាតិ | 4 |
| ការស្រាវជ្រាវ | 4 |
| និស្សិត | 4 |
| បច្ចេកវិទ្យា | 3 |
| រដ្ឋាភិបាល | 3 |
| វិទ្យាសាស្ត្រ | 3 |
| សន្តិភាព | 3 |

ប្រភព: អ្នកនិពន្ធ

## លទ្ធផលរកឃើញ និងការពិភាក្សា

ក្នុងកំឡុងពេលប្រមូលទិន្នន័យ អ្នកចូលរួមបានផ្តល់ចម្លើយផ្សេងៗគ្នាអំពីនិយមន័យរបស់ពាក្យ "អន្តរជាតូបនីយកម្ម" ដោយខ្លះបានលើកថា វាជាភាពជាដៃគូជាមួយស្ថាប័នឬសហសេវិកបរទេស អាហារូបករណ៍នៅក្រៅប្រទេស និងកម្មវិធីផ្លាស់ប្តូរនិស្សិតនិងបុគ្គលិក កិច្ចសហការស្រាវជ្រាវ កម្មវិធីសិក្សាអន្តរជាតិ និងជាពិសេស ការប្រើភាសាអង់គ្លេសជាមធ្យោបាយសម្រាប់ការបង្រៀននិងរៀន។ តាមមតិរបស់អ្នកចូលរួម SI1 អន្តរជាតូបនីយកម្មសំដៅដល់ ការសិក្សានៅបរទេសរបស់និស្សិត និងបុគ្គលិកតាមរយៈ អាហារូបករណ៍ និងកម្មវិធីផ្លាស់ប្តូរនិស្សិត និងបុគ្គលិក។ វាជា "អន្តរកម្មឥតព្រំដែន" ឬជា "អន្តរកម្មឆ្លងវប្បធម៌" ដែលជាប់ពាក់ព័ន្ធនឹងការចូលរួមនៅកម្រិតតំបន់ និងសកល។ ប៉ុន្តែ ចំណុចគួរឲ្យកត់សម្គាល់ដ៏សំខាន់មួយ គឺអ្នកចូលរួមភាគច្រើនហាក់ដូចជានិយាយត្រឹមតែការសិក្សាក្រៅប្រទេស និងការអនុម័តយកភាសាអង់គ្លេសមកប្រើក្នុងកម្មវិធីសិក្សាប៉ុណ្ណោះ។ មានអ្នកចូលរួមតិចនាក់ណាស់ដែលមានការយល់ដឹងទូលំទូលាយពី អន្តរជាតូបនីយកម្ម ដោយឲ្យនិយមន័យពាក្យនេះថាជា សកម្មភាពអន្តរជាតិច្រើនបែបយ៉ាង ទាំងនៅក្នុងស្រុក និងក្រៅស្រុក។ ដូចអ្នកចូលរួម PI1 បានបញ្ជាក់ច្បាស់ "វាមិនមែនមានន័យថា យើងត្រូវតែចេញទៅក្រៅ [ប្រទេស] ដើម្បីចូលរួមសកម្មភាពអន្តរជាតូបនីយកម្មនោះទេ។ យើងក៏អាចធ្វើអន្តរជាតូបនីយកម្ម នៅក្នុងប្រទេសកម្ពុជាបានដូចគ្នាដែរ"។

សម្ភាសន៍ស៊ីជម្រៅ បានផ្តល់គំនិតបន្ថែមទៀតថា កង្វះការយល់ដឹងពីអន្តរជាតូបនីយកម្ម នៅតាមគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា កើតមានជាសំខាន់ដោយសារ កង្វះយុទ្ធសាស្ត្រ និងគោលនយោបាយអន្តរជាតូបនីយកម្ម ទាំងនៅកម្រិតស្ថាប័ន និងកម្រិតជាតិ។ ចំណុចនេះ បានបង្ហាញយ៉ាងច្បាស់អំពីការតម្រង់ទិសនៃការអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជាសព្វថ្ងៃ ទោះបីពាក្យ "អន្តរជាតិ" មានចុះនៅក្នុងចក្ខុវិស័យរបស់សាកលវិទ្យាល័យ ៤ ក្នុងចំណោមសាកលវិទ្យាល័យ ៦ ដែលស្ថិតក្នុងការស្រាវជ្រាវនេះក្តី។ រូបភាព១ បង្ហាញថា សមាសភាគអន្តរជាតិ ជាចំណែកដ៏សំខាន់មួយនៃចក្ខុវិស័យរបស់គ្រឹះស្ថានឧត្តមសិក្សាទាំងនោះ។

ទាក់ទងនឹងទស្សនៈវិជ្ជមានលើ ការធ្វើអន្តរជាតូបនីយកម្មវិញ ហេតុផលផ្នែកសិក្សាស្រាវជ្រាវ ត្រូវបានយកមកពិភាក្សាយ៉ាងទូលំទូលាយក្នុងការស្រាវជ្រាវនេះ។ អ្នកចូលរួម PI1 បានចង្អុលបង្ហាញថា សកម្មភាពអន្តរជាតូបនីយកម្មអាចជួយបង្កើនគុណភាពការបង្រៀននិងរៀន ក៏ដូចជា ជួយលើកមុខមាត់ស្ថាប័នរបស់គាត់ផងដែរ។ គាត់ផ្តល់គំនិតបន្ថែមថា ស្ថាប័នរបស់គាត់ បានអនុម័តយកកម្មវិធីសិក្សា ដែលមានការទទួលស្គាល់ជាអន្តរជាតិ និងប្រើប្រាស់ភាសាអង់គ្លេស ជាមធ្យោបាយក្នុងការបង្រៀន ដើម្បីដើរឲ្យទាន់ការផ្លាស់ប្តូរយ៉ាងលឿននៃ សាកលភាវូបនីយកម្ម។ អ្នកចូលរួមម្នាក់ទៀតមកពីសាកលវិទ្យាល័យរដ្ឋ ក៏បានយល់ស្របនឹងមតិលើកឡើងខាងលើ ហើយបានបន្ថែមទៀតថា ដៃគូអន្តរជាតិ អាចជួយកសាងហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងសម្រួលការផ្សេងៗរបស់ស្ថាប័នគាត់ ក្នុងនោះមានទាំងមន្ទីរពិសោធន៍សម្រាប់ធ្វើការស្រាវជ្រាវ ដែលអាចមានតម្លៃខ្ពស់ហួសពីសមត្ថភាពរបស់ គ្រឹះស្ថានឧត្តមសិក្សាស្ទើរតែទាំងអស់នៅកម្ពុជា (SI1)។ ក្រៅពីហេតុផលផ្នែកសិក្សា នៅមានហេតុផលផ្នែកសង្គម-វប្បធម៌ទៀត ព្រោះមានអ្នកចូលរួមមួយចំនួនបានលើកឡើងពីឱកាសសម្រាប់ការចែករំលែកវប្បធម៌តាមរយៈ កម្មវិធីផ្លាស់ប្តូរនិស្សិត ជាដើម។ អ្នកចូលរួម PI1 បានលើកថា "ការទាក់ទាញនិស្សិតអន្តរជាតិ ឲ្យចូលមកសិក្សាក្នុងសកលវិទ្យាល័យរបស់

យើងកាន់តែច្រើន នឹងផ្តល់ឱកាសឲ្យនិស្សិតយើងរៀនសូត្របានច្រើនថែមទៀតអំពីវប្បធម៌បរទេស ហើយក្នុងពេលជាមួយគ្នានិស្សិតយើងក៏អាចចែករំលែកវប្បធម៌ និងប្រពៃណីរបស់យើងទៅដល់និស្សិតបរទេសដែរ"។ គាត់គិតថា ការយល់ដឹងអន្តរវប្បធម៌មានសារៈសំខាន់បំផុត ដើម្បីលើកស្ទួយការយោគយល់គ្នាទៅវិញទៅមក និងសន្តិភាពក្នុងចំណោមប្រជាជាតិទាំងឡាយ។ មិនតែប៉ុណ្ណោះ ការនាំយកនិស្សិត និងសាស្ត្រាចារ្យអន្តរជាតិឲ្យបានកាន់តែច្រើនមកក្នុងសាកលវិទ្យាល័យ ក៏ត្រូវចំណាយអស់តិចជាងការបញ្ជូននិស្សិតទៅបរទេសដែរ។

ហេតុផលពីរផ្សេងទៀត ត្រូវបានលើកយកមកបកស្រាយតិចតួចណាស់ក្នុងអំឡុងពេលនៃការសិក្សានេះ។ ហេតុផលផ្នែកនយោបាយ បានផុសឡើងតែក្នុងពេលសម្ភាសន៍ជាមួយអ្នកធ្វើការក្នុងវិស័យសាធារណៈ ដោយពួកគាត់លើកឡើងពីកម្មវិធីជំនួយផ្នែកអប់រំដែលទទួលបានមូលនិធិពី ទីភ្នាក់ងាររដ្ឋាភិបាលនានា ក្នុងន័យលើកកម្ពស់ទំនាក់ទំនងរវាងប្រទេសមួយ នឹងប្រទេសមួយ។ ក្នុងការពិភាក្សាពីហេតុផលសេដ្ឋកិច្ចវិញ មានការផ្តោតតែលើការចូលក្នុង សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលបានចាប់ដំណើរការតាំងពីខែធ្នូ ២០១៥ មក ដើម្បីលើកកម្ពស់លំហូរដោយសេរីនៃកម្លាំងពលកម្ម មូលធន និងទំនិញ ក្នុងចំណោមប្រទេសនានានៅក្នុងតំបន់។ ដូចនេះ កម្ពុជាត្រូវធ្វើការកាន់តែខ្លាំងឡើង ដើម្បីផលិតធនធានមនុស្សឲ្យមានសមត្ថភាពខ្ពស់ ដែលអាចជួយលើកកម្ពស់កម្លាំងប្រកួតប្រជែងរបស់កម្ពុជាទាំងនៅក្នុងតំបន់ និងក្នុងពិភពលោក។ ក្រៅពីនេះ មានការពិភាក្សាតិចតួចណាស់ ពី យុទ្ធសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាក្នុងការធ្វើអន្តរជាតូបនីយកម្ម ដូចជា ការទាក់ទាញនិស្សិតបរទេស និងអ្នកស្រាវជ្រាវ ដើម្បីជួយបង្កើនប្រាក់ចំណូលរបស់សាកលវិទ្យាល័យជាដើម។ យើងទទួលស្គាល់គ្រប់គ្នាថា បញ្ហានេះ បណ្តាលមកពីកង្វះគុណភាព និងការខ្សត់ធនធានរបស់គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាភាគច្រើន។ ម្យ៉ាងទៀត អ្នកចូលរួមជាច្រើនរូបបានលើកមតិថា មានសកលវិទ្យាល័យតិចតួចណាស់ដែលផ្តល់កម្មវិធីសិក្សាជាភាសាអង់គ្លេស ហើយនេះជារបាំងដ៏ធំមួយរារាំងស្ថាប័នឧត្តមសិក្សាកម្ពុជា ក្នុងការចូលរួមឲ្យបានកាន់តែច្រើនជាមួយនឹងសមភាគីបរទេសនានា។

ថ្វីបើមានទស្សនៈវិជ្ជមាន ដូចលើកឡើងនៅខាងលើក្តី ក៏មានអ្នកចូលរួមខ្លះបានរិះគន់ដល់អន្តរជាតូបនីយកម្មដែរ។ អ្នកចូលរួម SI1 អះអាងថា ស្ថាប័នរបស់គាត់មិនទាន់ត្រៀមខ្លួនរួចរាល់ដើម្បីចូលរួមជាមួយសហគមន៍សិក្សាស្រាវជ្រាវក្នុងតំបន់ និងអន្តរជាតិទេ ដោយសារកង្វះថវិកា និងសមត្ថភាពរបស់ស្ថាប័នហើយរហូតមកទល់បច្ចុប្បន្ន សាកលវិទ្យាល័យរបស់គាត់ បានកំណត់កម្មវិធីសិក្សារបស់ខ្លួនត្រឹមតែសម្រាប់ តម្រូវការក្នុងស្រុកប៉ុណ្ណោះ។ តាមយោបល់គាត់ ក្នុងដំណើរការ AEC នេះ ការចូលរួមធ្វើអន្តរជាតូបនីយកម្មគឺមិនអាចជៀសផុតទេ ប៉ុន្តែបើសិនគ្មានការរៀបចំ និងការត្រៀមខ្លួនរួចរាល់ ស្ថាប័នរបស់គាត់នឹងត្រូវវង្វេងសម្លាធពីបរទេស ឲ្យទទួលយកចំណេះដឹង និងមនោគមវិជ្ជាពីខាងក្រៅ។ អ្នកចូលរួម PI1 មានគំនិតដូចគ្នាដោយអះអាងថា នៅកម្ពុជា ជាការធម្មតាទេដែលសាស្ត្រាចារ្យ ឬគ្រូបង្រៀន ចម្លងឯកសារ និងខ្លឹមសារផ្សេងៗពីបរទេស [ដោយគ្មានការកែតម្រូវឲ្យត្រូវនឹងបរិបទក្នុងប្រទេស] សម្រាប់ប្រើប្រាស់ក្នុងការបង្រៀន។

ម្យ៉ាងទៀត កម្មវិធីអន្តរជាតិមួយចំនួន គឺត្រូវបានតម្រង់ទិសជាស្រេចពីម្ចាស់ជំនួយ ដោយផ្តល់លទ្ធភាពតិចតួចបំផុតឲ្យមានការកែតម្រូវទៅតាមបរិបទក្នុងស្រុក (អ្នកចូលរួម SI2)។ អ្នកចូលរួមខ្លះក៏បានលើកនូវ ក្តីបារម្ភពីការប្រើប្រាស់កាន់តែច្រើនឡើងនូវ ភាសាអង់គ្លេស និងភាសាផ្សេងៗទៀត ដូចជា ចិន កូរ៉េ និង ជប៉ុន ជាជាងភាសាក្នុងស្រុក ដោយវានឹងមានផលប៉ះពាល់អវិជ្ជមានដល់ វប្បធម៌ ចំណេះដឹង និងតម្លៃរបស់ជាតិ។

## ការផ្តល់មតិ

ការពិភាក្សាខាងលើ បានបង្ហាញថា អន្តរជាតូបនីយកម្មនៅតែជាគំនិតថ្មីមួយសម្រាប់កម្ពុជា ដោយមនុស្សភាគច្រើននៅតែផ្សារភ្ជាប់វាទៅនឹងទម្រង់បែបប្រពៃណីនៃពាក្យនេះ ដូចជា ការសិក្សាក្រៅប្រទេស ឬការប្រើភាសាបរទេសជាមធ្យោបាយក្នុងការបង្រៀន។ ខណៈដែលអ្នកចូលរួមភាគច្រើនបានមើលឃើញអន្តរជាតូបនីយកម្មជាឱកាសល្អ ក្តីបារម្ភពីបញ្ហា ដូចជា ឥទ្ធិពលគ្របដណ្តប់វប្បធម៌ ភាសា ចំណេះដឹង និងមនោគមវិជ្ជាផ្សេងៗរបស់បរទេស ក៏មានលើកឡើងដែរ។ ខាងក្រោមនេះ ជាមតិយោបល់មួយចំនួនរបស់អ្នកស្រាវជ្រាវ ដើម្បីចូលរួមជួយរុញច្រានឧត្តមសិក្សានៅកម្ពុជាឲ្យមានការធ្វើអន្តរជាតូបនីយកម្ម៖

ទី១ ដោយហេតុថា នៅមានមនុស្សជាច្រើនមិនទាន់បានយល់ដឹងពីគោលគំនិតនៃ អន្តរជាតូបនីយកម្មឧត្តមសិក្សា និងសារៈសំខាន់របស់វានោះ គឺជាការចាំបាច់បំផុត ដែលរដ្ឋាភិបាលមានផ្តល់នូវ គោលការណ៍ណែនាំទូទៅ និងយុទ្ធសាស្ត្រអន្តរជាតូបនីយកម្ម ដល់គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា។ ក្នុងនេះ គួរមានគំនិតផ្តួចផ្តើមផ្សេងៗ តាំងពីការផ្តល់អាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេស រហូតដល់ការបង្កើតកម្មវិធីសម្រាប់ទាក់ទាញជនបរទេស ដែលមានទេពកោសល្យ និងជនកម្ពុជាដែលបានទទួលការអប់រំនៅក្រៅប្រទេសឲ្យចូលមកកម្ពុជា ដើម្បីជួយកសាងប្រព័ន្ធអប់រំរបស់កម្ពុជាឡើងវិញ។

ទី២ ច្បាស់ហើយ គ្រឹះស្ថានឧត្តមសិក្សាជាច្រើននៅកម្ពុជានៅមិនទាន់បានយល់ច្បាស់ពី អន្តរជាតូបនីយកម្មកម្មវិធីសិក្សាហើយមិនសូវមានស្ថាប័នឧត្តមសិក្សានៅកម្ពុជាច្រើនទេ ដែលបានអនុវត្តកម្មវិធីប្រភេទនេះ។ វាជាការពិតដែលគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាភាគច្រើនបានអនុម័តយកកម្មវិធីសិក្សា និងឯកសារបង្រៀននិងរៀនពីបរទេស ដោយមានការកែសម្រួលឲ្យស៊ីនឹងបរិបទក្នុងស្រុកតែបន្តិចបន្តួចប៉ុណ្ណោះ។ ការធ្វើបែបនេះ បានចោទជាបញ្ហាដ៏ធ្ងន់ធ្ងរមួយពីភាពពាក់ព័ន្ធនៃ ប្រព័ន្ធអប់រំនៅកម្ពុជា (ឬបញ្ហាគ្របដណ្តប់លើការសិក្សាស្រាវជ្រាវ ឬភាពពឹងផ្អែកផ្នែកវប្បធម៌)។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ កម្ពុជាគួរអនុវត្តតាមយុទ្ធសាស្ត្របីរបស់ Mazrui គឺមាន យុទ្ធសាស្ត្រធ្វើមូលដ្ឋានីយកម្ម យុទ្ធសាស្ត្រធ្វើពិពិធកម្ម និងយុទ្ធសាស្ត្រទប់ទល់ការជ្រៀតចូល។

កម្ពុជាគួរកែសម្រួលចំណេះដឹងបរទេស ឲ្យសមស្របទៅនឹងបរិបទក្នុងស្រុក។ និស្សិតសាកលវិទ្យាល័យម្នាក់ៗ ទោះក្នុងមុខជំនាញអ្វីក៏ដោយ គួរតែមានការយល់ដឹងច្បាស់លាស់ពីវប្បធម៌ ភាសា និង ប្រវត្តិសាស្ត្រកម្ពុជា។ គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា គួរដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់ខ្លួននូវ ចំណេះដឹងពីប្រទេសឯទៀតនៅអាស៊ាន និងជុំវិញពិភពលោក ហើយកម្ពុជាក៏គួរកសាង(ឡើងវិញ)នូវប្រព័ន្ធអាហារូបករណ៍របស់ខ្លួន ជាពិសេសតាមរយៈការបង្កើតនិងគួបផ្សំភាពតឹងរឹងនៃការស្រាវជ្រាវជាមួយនឹង ចំណេះដឹងក្នុងស្រុកក្នុងមុខវិជ្ជាផ្សេងៗ ព្រមទាំងលើកស្ទួយវាជាមួយគ្នានឹង ភាសា និងវប្បធម៌កម្ពុជា នៅកម្រិតអន្តរជាតិ។

ឯកសារស្រាវជ្រាវនេះ ផ្ដល់នូវទិដ្ឋភាពទូទៅនៃការឲ្យនិយមន័យ និងការយល់ឃើញផ្សេងៗ លើអន្តរជាតូបនីយកម្មឧត្តមសិក្សានៅកម្ពុជា។ ដោយផ្អែកលើការសិក្សាជាមូលដ្ឋាននេះ ការស្រាវជ្រាវនាពេលអនាគត អាចពិនិត្យឲ្យកាន់តែស៊ីជម្រៅថែមទៀតពី ខ្លឹមសារ និងហេតុផលនៃអន្តរជាតូបនីយកម្ម ដោយវិភាគតាមទស្សនៈរបស់អ្នកពាក់ព័ន្ធដទៃទៀត។ ទិដ្ឋភាពផ្សេងៗទៀតនៃអន្តរជាតូបនីយកម្មនៅកម្ពុជា ដូចជា ភាពចល័តចេញទៅក្រៅនិងចូលមកក្នុងប្រទេស ការប្រើប្រាស់ភាសាបរទេសនិងកម្មវិធីសិក្សាអន្តរជាតិ ការបង្កើតសាខារបស់គ្រឹះស្ថានឧត្តមសិក្សាបរទេសនៅកម្ពុជា និងភាពជាដៃគូឆ្លងដែនក្នុងការបង្រៀន និងការស្រាវជ្រាវ គួរមានការសិក្សាឲ្យបានស៊ីជម្រៅជាងនេះ។

## ឯកសារយោង


Altbach, Philip G. 2013. "The Imperial Tongue: English as the Dominating Academic Language." In *The International Imperative in Higher Education*, 1–6. Global Perspectives on Higher Education Vol 27. Rotterdam: Sense Publishers. http://link.springer.com/chapter/10.1007/978-94-6209-338-6_1.

Altbach, Philip G. 2014. "MOOCs as Neocolonialism: Who Controls Knowledge?" *International Higher Education* 75 (March): 5–7. doi:10.6017/ihe.2014.75.5426.

Altbach, Philip G., and Jane Knight. 2007. "The Internationalization of Higher Education: Motivations and Realities." *Journal of Studies in International Education* 11 (3-4): 290–305. doi:10.1177/1028315307303542.

Batalova, Jeanne, Andriy Shymonyak and Guntur Sugiyarto. 2017. "Firing Up Regional Brain Networks: The Promise of Brain Circulation in the ASEAN Economic Community." Mandaluyong City, Philippines: Asian Development Bank. https://www.adb.org/publications/regional-brain-networks-asean.

Clayton, Thomas. 2006. *Language Choice in a Nation under Transition: English Language Spread in Cambodia*. Language Policy Vo. 5. Springer Science+Business Media.

Creswell, John W. 2012. *Educational Research: Planning, Conducting, and Evaluating Quantitative and Qualitative Research*. 4th ed. Boston, MA: Pearson.

Hawawini, Gabriel. 2016. *The Internationalization of Higher Education and Business Schools*. Springer Briefs in Business. Singapore: Springer. http://www.springer.com/gp/book/9789811017551.

Hoppers, Catherine A. Odora. 2000. "The Centre-Periphery in Knowledge Production in the Twenty-First Century." *Compare: A Journal of Comparative and International Education* 30 (3): 283–91. doi:10.1080/713657471.

Hughes, Rebecca. 2008. "Internationalisation of Higher Education and Language Policy: Questions of Quality and Equity." *Higher Education Management and Policy* 20 (1): 1–18. doi:10.1787/hemp-v20-art6-en.

Knight, Jane. 2004. "Internationalization Remodeled: Definition, Approaches, and Rationales." *Journal of Studies in International Education* 8 (1): 5–31. doi:10.1177/1028315303260832.

Knight, Jane. 2008. *Higher Education in Turmoil: The Changing World of Internationalization*. Global Perspectives on Higher Education Vol 13. Rotterdam: Sense Publishers. https://www.sensepublishers.com/media/475-higher-education-in-turmoil.pdf.

Larsen, Marianne A. 2016. *Internationalization of Higher Education: An Analysis through Spatial, Network, and Mobilities Theories*. New York: Palgrave Macmillan. http://www.palgrave.com/gb/book/9781137533449.

Mazrui, Ali. 1975. "The African University as Multinational Cooperation: Problems of Penetration and Dependency." *Harvard Educational Review* 45 (2): 191–210.

Pit, Chamnan, and David Ford. 2004. "Cambodian Higher Education: Mixed Visions." In *Asian Universities: Historical Perspectives and Contemporary Challenges*, edited by Philip G. Altbach and Toru Umakoshi, 333–62. Baltimore, MA: John Hopkins University Press.

UIS (UNESCO Institute for Statistics). 2016. "Global Flow of Tertiary-Level Students." http://glossary.uis.unesco.org/Education/Pages/international-student-flow-viz.aspx.

UIS. 2017. "Education : Outbound Internationally Mobile Students by Host Region." May. http://data.uis.unesco.org/#.

Wit, Hans de. 2002. *Internationalization of Higher Education in the United States of America and Europe: A Historical, Comparative, and Conceptual Analysis*. Westport, CT: Greenwood Publishing Group.

Wit, Hans de, Fiona Hunter, Laura Howard and Eva Egron-Polak. 2015. "Internationalisation of Higher Education." Brussels: European Parliament's Committee on Culture and Education. http://www.europarl.europa.eu/studies.